ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ ១០៣៩

ចុះថ្ងៃទី ០៦_១២_២០១១

<u>សាលដីកាព្រហ្មទណ្ឌ</u>

លេខ : ៦៤ "ក្រ.II សទ"

ចុះថ្ងៃទី ២៧_០៧_២០១២

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជំរះក្តី ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ០៦ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលសវនាការសាលាឧទ្ធរណ៍ នាថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០១២ ដោយមានសមាសភាពដូចខាងក្រោម:

**<u>ក្រុមប្រឹក្សាជំនុំជម្រះ</u>**

- ឯកឧត្តម [redacted] ជាប្រធាន
- ឯកឧត្តម [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

**<u>តំណាងមហាអយ្យការ</u>**

លោក [redacted]

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោក[redacted]

**ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ១០៣៩ ចុះថ្ងៃទី ០៦ ខែធ្នូ ឆ្នាំ២០១១ ដែលមាន:**

១- ជនជាប់ចោទឈ្មោះ [redacted] **ធី** ភេទប្រុស អាយុ ៣៧ឆ្នាំ ជាតិខ្មែរ កើត និងរស់នៅសព្វថ្ងៃភូមិព្រៃកោះ [redacted] ខេត្តកំពង់ស្ពឺ មុខរបរធ្វើស្រែ ឪពុកឈ្មោះ[redacted] ម្តាយឈ្មោះ[redacted] ប្រពន្ធឈ្មោះ [redacted] មានកូន ២នាក់ ទោសពីមុនគ្មាន (ចុងបណ្តឹងឧទ្ធរណ៍) ។

២- ជនជាប់ចោទឈ្មោះ [redacted] **មាណ (កែវ មាណ)** ភេទប្រុស អាយុ ៣១ឆ្នាំ ជាតិខ្មែរ កើត និងរស់នៅសព្វថ្ងៃ[redacted] ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ មុខរបរធ្វើស្រែ ឪពុកឈ្មោះ[redacted] ម្តាយឈ្មោះ[redacted] ប្រពន្ធឈ្មោះ[redacted]មានកូន ៤នាក់ ទោសពីមុនគ្មាន (ចុងបណ្តឹងឧទ្ធរណ៍) ។

៣- ជនជាប់ចោទឈ្មោះ[redacted] **ទូច ហៅ ណូ** ភេទប្រុស អាយុ ២៩ឆ្នាំ ជាតិខ្មែរ កើត និងរស់នៅសព្វថ្ងៃ [redacted] ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ មុខរបរធ្វើស្រែ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] នៅលីវ ទោសពីមុនធ្លាប់ជាប់ពន្ធនាគារពីបទបង្ករបួស (ចុងបណ្តឹងឧទ្ធរណ៍) ។

មានលោក[redacted] **សុផង់** មេធាវីការពារជនជាប់ចោទ ។

**ជាប់ចោទពីបទៈ ឃាតកម្មគិតទុកជាមុន** ប្រព្រឹត្តនៅភូមិព្រៃកោះ ឃុំវល្លិ៍ស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោស តាមមាត្រា ៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សុខា** ភេទស្រី អាយុ ៤៦ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ ទីលំនៅសព្វថ្ងៃភូមិថ្មុកឈើទាល សង្កាត់សុព័រទេព ក្រុងច្បារមន ខេត្តកំពង់ស្ពឺ (ចុងបណ្តឹងឧទ្ធរណ៍)។

**ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ**

កាលពីថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ២០០៩ វេលាម៉ោង ១០យប់ ឈ្មោះ [redacted] **ធី** ឈ្មោះ [redacted] **មាណ** និងឈ្មោះ [redacted] **ទូច** បានបបួលឈ្មោះ [redacted] **ម៉ន** ជាជនរងគ្រោះឱ្យមកផឹកស្រាក្នុងគោលបំណងមានគំរោង សម្លាប់ឈ្មោះ [redacted] **ម៉ន** ដោយខ្លាចឈ្មោះ [redacted] **ម៉ន** ប្រាប់សមត្ថកិច្ចពីរឿងដែលឈ្មោះ [redacted] **មាណ** បានឱ្យ ជនល្មើសមួយក្រុមស្នាក់នៅសម្រាប់រង់ចាំបាញ់សម្លាប់មេឃុំឈ្មោះ [redacted] **ខុន** ទើបឈ្មោះ [redacted] **មាណ** ឈ្មោះ [redacted] **ធី** និងឈ្មោះ [redacted] **ទូច** សម្រេចចិត្តសម្លាប់ [redacted] **ម៉ន** ចោល។ លុះដល់ថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០០៩ ជាថ្ងៃកើតហេតុ ពេលនោះឈ្មោះ [redacted] **ម៉ន** មកងូតទឹកស្ទឹង ស្រាប់តែឈ្មោះ [redacted] **ធី** ស្ទុះទៅច្របាច់កឈ្មោះ [redacted] **ម៉ន** ពីក្រោយ ហើយឈ្មោះ [redacted] **ទូច** បានស្ទុះទៅជួយចាប់ច្របាច់កដែរ ឯឈ្មោះ [redacted] **មាណ** បានយកកំណាត់ ឈើជ្រុងវាយមកលើមុខឈ្មោះ [redacted] **ម៉ន** ចំនួន ២កំណាត់ឈើ ហើយក៏បោះឈើនោះចូលទៅក្នុងទឹកស្ទឹង។ នៅពេលឈ្មោះ **សូ ម៉ន** ស្លាប់ហើយ ឈ្មោះ [redacted] **ទូច** និងឈ្មោះ [redacted] **ធី** បានរត់មកដេកនៅផ្ទះ [redacted] **ជា** ហើយឈ្មោះ [redacted] **មាណ** អូសសាកសពឈ្មោះ [redacted] **ម៉ន** ទម្លាក់ចូលទៅក្នុងទឹកស្ទឹងទៅ។

**បានឃើញ បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ២៩ ឃ ចុះថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តកំពង់ស្ពឺ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:**

១- កែប្រែបទល្មើស ពីបទ ឃាតកម្មគិតទុកជាមុន មកបទល្មើស មនុស្សឃាតដោយចេតនា វិញ។

២- ផ្តន្ទាទោសឈ្មោះ

**ក-** [redacted] **មាណ** (កែវ មាណ) ភេទប្រុស អាយុ ៣១ឆ្នាំ ទីលំនៅកំណើត និងមុនចាប់ខ្លួននៅ ភូមិព្រៃកោះ [redacted] ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ប្រពន្ធឈ្មោះ [redacted] ដាក់ពន្ធនាគារកំណត់១១ឆ្នាំ (ដប់មួយឆ្នាំ) គិតពីថ្ងៃឃុំខ្លួនថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០០៩ ពីបទ **មនុស្សឃាតដោយចេតនា** ប្រព្រឹត្តនៅភូមិព្រៃកោះ ឃុំវល្លិ៍ស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៤ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

**ខ-** ឱ្យឈ្មោះ [redacted] **ទូច** ភេទប្រុស អាយុ ២៩ឆ្នាំ ទីលំនៅកំណើត និងមុនចាប់ខ្លួន[redacted] ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] នៅលីវ និងឈ្មោះ [redacted] ភេទប្រុស អាយុ ៣៧ឆ្នាំ ទីលំនៅកំណើត និងមុនចាប់ខ្លួននៅភូមិព្រៃកោះ ឃុំវល្លិ៍ស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ប្រពន្ធឈ្មោះ [redacted] រួចផុតពីការចោទប្រកាន់ពី បទល្មើសខាងលើ។

៣- បង្គាប់ឱ្យឈ្មោះ[redacted]មាណ ([redacted]មាណ) សងសំណងជម្ងឺចិត្តចំនួន ៤.០០០.០០០រៀល (បួនលានរៀល) ទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សុខា** សំណូមពរលើសពីនេះត្រូវបដិសេធចោល ។ បើឈ្មោះ [redacted] **មាណ** ([redacted] **មាណ**) រឹងរូស ត្រូវដាក់គុកបង្ខំរូបកាយតាមច្បាប់ ។

៤- សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ និងដើមបណ្តឹង រដ្ឋប្បវេណី បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

- បានឃើញ សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ២០១០ របស់លោក [redacted] តំណាងអយ្យការ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ២៩ ឃ ចុះថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តកំពង់ស្ពឺ ត្រង់ចំណុច **ខ** នៃសេចក្តីសម្រេច ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

- បានឃើញរបាយការណ៍រឿងព្រហ្មទណ្ឌរបស់ចៅក្រមរបាយការណ៍ សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ។

**<u>នាពេលសវនាការ</u>**

- ជនជាប់ចោទឈ្មោះ [redacted] **ធី** (អវត្តមាន)
- ជនជាប់ចោទឈ្មោះ [redacted]**មាណ** (អវត្តមាន)
- ជនជាប់ចោទឈ្មោះ [redacted]**ទូច** (អវត្តមាន)
- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សុខា** (អវត្តមាន)

**តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ធ្វើសេចក្តីសន្និដ្ឋានថា:** ផ្អែកតាមអង្គហេតុ និងភស្តុតាងនៅក្នុងសំណុំរឿងអាចឱ្យយើងកំណត់បានថា បទល្មើសដែលបានកើតឡើងនេះ គឺបទ ឃាតកម្មគិតទុកជាមុន ពុំមែនបទល្មើស មនុស្សឃាតដោយចេតនា នោះឡើយ ហេតុនេះ គប្បីសភាព្រហ្មទណ្ឌធ្វើការពិចារណាឱ្យបានច្បាស់លាស់ ។ សំអាងហេតុ និងសេចក្តីសម្រេចនៃសាលក្រមព្រហ្មទណ្ឌលេខ ២៩ ឃ ចុះថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តកំពង់ស្ពឺ គប្បីសភាព្រហ្មទណ្ឌធ្វើការពិចារណាឡើងវិញ ។

លោក [redacted] **សុផង់** មេធាវីការពារជនជាប់ចោទ ធ្វើសេចក្តីសន្និដ្ឋានថា: ចម្លើយរបស់កូនក្តីខ្លួននៅនគរបាល គឺជាចម្លើយដែលសមត្ថកិច្ចធ្វើទារុណកម្ម ។ ហើយសេចក្តីសម្រេចរបស់សាលាដំបូងខេត្តកំពង់ស្ពឺ មានលក្ខណៈត្រឹមត្រូវ សំណូមពរ សូមសភាព្រហ្មទណ្ឌមេត្តាសម្រេចឱ្យកូនក្តីខ្លួនរួចផុតពីបទចោទប្រកាន់ផង ។

- ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ
- ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
- ក្រោយពីបានពិនិត្យពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

## សភាព្រហ្មទណ្ឌ យល់ឃើញថា

១- បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ២០១០ របស់លោក [redacted] ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តកំពង់ស្ពឺ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ២៩ ឃ ចុះថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តកំពង់ស្ពឺ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច បានធ្វើឡើងត្រឹមត្រូវក្នុងកំណត់ច្បាប់ សភាព្រហ្មទណ្ឌទទួលជំនុំជម្រះបាន យោងតាមមាត្រា ៣៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២- តាមលទ្ធផលនៃកិច្ចពិភាក្សា ឃើញថា តាមចម្លើយរបស់ឈ្មោះ [redacted] **ធី** និងឈ្មោះ [redacted] **ទូច** បានឆ្លើយបដិសេធថា ខ្លួនមិនបានចូលរួមសម្លាប់ជនរងគ្រោះទេ តែទទួលស្គាល់ថា ពួកខ្លួនពិតជាបានចូលរួមស៊ីផឹកជាមួយឈ្មោះ [redacted] **មាណ** និងជនរងគ្រោះ ពិតមែន។ នៅពេលស៊ីផឹកនោះ ពិតជាមានទំនាស់ពាក្យសំដីរវាងឈ្មោះ [redacted] **មាណ** និងជនរងគ្រោះ។ បន្ទាប់មកពួកខ្លួនទៅផ្ទះ ដេកនៅផ្ទះរហូតទល់ភ្លឺ។ ប៉ុន្តែចម្លើយនេះគ្រាន់តែជាចម្លើយដោះសារយករួចខ្លួនប៉ុណ្ណោះ ព្រោះតាមចម្លើយសារភាពរបស់ជនជាប់ចោទនៅមុខនគរបាលថា ពួកខ្លួនពិតជាបានធ្វើសកម្មភាពវាយសម្លាប់ជនរងគ្រោះពិតមែន។

៣- កាលពីថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០០៩ ជនជាប់ចោទឈ្មោះ [redacted] **មាណ** ឈ្មោះ [redacted] **ធី** និង ឈ្មោះ [redacted] **ទូច** ពិតជាបានរួមគំនិតគ្នាវាយសម្លាប់ជនរងគ្រោះឈ្មោះ [redacted] **ម៉ន** ប្រាកដមែន ដោយខឹងនឹងជនរងគ្រោះប្រាប់សមត្ថកិច្ចថា ឈ្មោះ [redacted] **មាណ** ជាអ្នកសមគំនិតក្នុងការធ្វើឃាតលើឈ្មោះ **ខុន** ដោយសង្ស័យថា ឈ្មោះ **ខុន** នេះជាគ្រូធ្មប់ ដោយឈ្មោះ [redacted] **ធី** ជាអ្នកចាប់ជនរងគ្រោះ ឈ្មោះ [redacted] **ទូច** ជាអ្នកច្របាច់កជនរងគ្រោះ ហើយឈ្មោះ [redacted] **មាណ** ជាអ្នកវាយជនរងគ្រោះ ដោយប្រើកំណាត់ឈើវាយទៅលើផ្ទៃមុខជនរងគ្រោះចំនួនពីរកំណាត់ឈើបណ្តាលឱ្យជនរងគ្រោះស្លាប់ភ្លាមនៅកន្លែងកើតហេតុ រួចក៏នាំគ្នាសែងជនរងគ្រោះទៅទម្លាក់ចោលក្នុងទឹកស្ទឹង។ ឃើញថា ជាអំពើមានធាតុផ្សំ និងភស្តុតាងដាក់បន្ទុកលើជនជាប់ចោទ ពីបទ ឃាតកម្មគិតទុកជាមុន តាមមាត្រា ៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ដែលគប្បីផ្តន្ទាទោសទោសជនទាំងនេះតាមច្បាប់។ ប៉ុន្តែ ដោយហេតុថា តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺមិនបានប្តឹងឧទ្ធរណ៍ត្រង់ចំណុចទី ១ ស្តីពីការកែប្រែបទល្មើសពីបទ ឃាតកម្មគិតទុកជាមុន ទៅជាបទ មនុស្សឃាតដោយចេតនានៃសាលក្រមព្រហ្មទណ្ឌលេខ ២៩ ឃ ចុះថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តកំពង់ស្ពឺ សភាព្រហ្មទណ្ឌមិនអាចធ្វើការកែប្រែបទល្មើសតាមច្បាប់បានទេ។ ហេតុដូច្នេះ សភាព្រហ្មទណ្ឌពិចារណាតែលើចំណុចទី ២ ខ នៃសាលក្រមនេះប៉ុណ្ណោះ។

៤- តាមសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ប្តឹងសុំសភាព្រហ្មទណ្ឌធ្វើការពិចារណាឡើងវិញលើសំអាងហេតុនៃសាលក្រមព្រហ្មទណ្ឌលេខ ២៩ ឃ ចុះថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តកំពង់ស្ពឺ ដោយលើកមូលហេតុថា ផ្អែកតាមអង្គហេតុ និងភស្តុតាងនៅក្នុងសំណុំរឿងអាចឱ្យយើងកំណត់បានថាបទល្មើសដែលបានកើតឡើងនេះ គឺបទ ឃាតកម្មគិតទុកជាមុន ពុំមែនបទល្មើស មនុស្សឃាតដោយចេតនា នោះឡើយ ដែលចំណុចនេះគប្បីសភាព្រហ្មទណ្ឌពិចារណា។

៥- ចំណុចទី ២ ខ នៃសាលក្រមព្រហ្មទណ្ឌលេខ ២៩ ឃ ចុះថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តកំពង់ស្ពឺ ដែលសម្រេចមកនេះពុំមានលក្ខណៈត្រឹមត្រូវតាមច្បាប់ឡើយ ដែលគប្បីសភាព្រហ្មទណ្ឌបដិសេធចោល ហើយសម្រេចជាថ្មីតាមការយល់ឃើញខាងលើ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១- ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ២០១០ របស់លោក [redacted] **សុភាង** ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តកំពង់ស្ពឺ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២- បដិសេធចំណុចទី ២ ខ នៃសាលក្រមព្រហ្មទណ្ឌលេខ ២៩ ឃ ចុះថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តកំពង់ស្ពឺ ចោលជាអសារបង់ ។

៣- ផ្តន្ទាទោសឈ្មោះ [redacted] **ធី** ភេទប្រុស អាយុ ៣៧ឆ្នាំ ជាតិខ្មែរ និងឈ្មោះ [redacted] **ទូច** ភេទប្រុស អាយុ ២៩ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ១១ឆ្នាំ (ដប់មួយឆ្នាំ) ពីបទ មនុស្សឃាតដោយចេតនា ប្រព្រឹត្តនៅភូមិព្រៃកោះ ឃុំវល្លិស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៤ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

៤- បន្តឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] **ធី** និងឈ្មោះ [redacted] **ទូច** តាមនីតិវិធីច្បាប់ ។

៥- សាលដីកានេះជំនុំជម្រះនៅថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០១២ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០១២ ចំពោះមុខមេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ។

បើកសិទ្ធិប្តឹងតវ៉ាក្នុងកំណត់ច្បាប់ ។

សាលដីកានេះ ចូលជាស្ថាពរ មានអានុភាពអនុវត្ត លើឈ្មោះ វ៉ាត់ ធី ក្រៅពីនោះពុំមានអានុភាពអនុវត្តឡើយ ។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់ គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។**

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] |

**បានឃើញ**

**ប្រធានសាលាឧទ្ធរណ៍**

យូ-ម៉ុនឡេង

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី ... ខែ ០២ ឆ្នាំ ២០១៤

**ក្រឡាបញ្ជី**

ពេជ្រ ដល្លាសម្បត្តិ